# បទបង្ហាញ

# ស្តីពីការសិក្សានិងអនុវត្ត វិធីសាស្ត្រវាយតម្លៃលិខិតបទដ្ឋានគតិយុត្ត (RIA)

# មាតិកា

1. សមាសភាពផ្នែក RIA ប្រចាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
2. គោលបំណង
3. គោលការណ៍ប្រតិបត្តិ RIA
4. ទិដ្ឋភាពនៃដំណាក់កាលអនុវត្ត RIA
5. ទម្រង់សម្រាប់វិភាគRIA(RIA Template)
6. របាយការណ៍វាយតម្លៃបឋម (PA) លើ អនុក្រឹត្យស្ដីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ និង..

# សមាសភាពភ្នាក់ងារអនុវត្ត RIA ប្រចាំក្រសួងកសិកម្ម ៖

1. លោក អ៊ុំ សារី ប្រធាន
2. លោក ហារ ផា អនុប្រធាន
3. លោក ខេង យ៉ាសិទ្ធ សមាជិក
4. លោក អ៊ិត ភុំ សមាជិក

# គោលបំណង/គោលដៅ

គម្រោង ស្តីពីការវាយតម្លៃលិខិតបទដ្ឋានគតិយុត្ត មានគោលបំណងកែលម្អភាពម៉ាំមួន នៃការធ្វើច្បាប់ ក្នុងគោលដៅពង្រឹងការប្រកួតប្រជែង និងប្រសិទ្ធភាពរបស់បញ្ញត្តិកម្ម តាមរយៈការបង្កើតនូវគោលការណ៍ប្រតិបត្តិទម្លាប់ល្អ ក្នុងការតាក់តែងលិខិតបទប្បញ្ញត្តិនៅតាមស្ថាប័នរាជរដ្ឋាភិបាល ។

## គោលការណ៍ប្រតិបត្តិនៃការវាយតម្លៃលិខិត

## បទដ្ឋានគតិយុត្ត(RIA)ទាំង៧

១/ បញ្ហា៖ ជាការកំណត់បញ្ហាដែលត្រូវដោះស្រាយ ដោយរៀបរាប់ពីមូលបញ្ហា និងអ្នករងផលប៉ះពាល់ និងផ្តល់ភស្តុតាងជាក់លាក់ព្រមទាំងពន្យល់ពីមូលហេតុដែលលិខិតបទដ្ឋានមាន ស្រាប់មិនអាចដោះស្រាយ ។

# គោលការណ៍ប្រតិបត្តិនៃការវាយតម្លៃលិខិតបទដ្ឋានគតិយុត្ត(RIA)ទាំង៧ (ត)

២/ គោលដៅ/គោលបំណង៖ ជាការកំណត់គោលដៅដែលត្រូវដោះស្រាយក្នុងរូបភាពជាលទ្ធផល ជាជាងមធ្យោបាយដើម្បីសម្រេចបានលទ្ធផល។

# គោលការណ៍ប្រតិបត្តិនៃការវាយតម្លៃលិខិតបទដ្ឋានគតិយុត្ត(RIA)ទាំង៧ (ត)

៣/ ជម្រើសៈជាការកំណត់ជម្រើសផ្សេងៗ ដោយបោះបង់ចោលនូវជម្រើសដែលមិនសមស្រប និងមិនអាចដោះស្រាយបាន។

# គោលការណ៍ប្រតិបត្តិនៃការវាយតម្លៃលិខិត បទដ្ឋានគតិយុត្ត(RIA)ទាំង៧ (ក)

៤/ ការវិភាគផលប៉ះពាល់៖

1. ការកំណត់នូវភារកិច្ចនិងប្រភេទចំណាយ
2. ប៉ាន់ស្មានលើបន្ទុកចំណាយ របស់ធុរកិច្ច និង របស់រដ្ឋាភិបាល
3. តើមានផលប៉ះពាល់ដល់យេនឌ័រឬទេ ?
4. តើមានប៉ះពាល់ដល់ការប្រកួតប្រជែង ដែរឬទេ ?

# គោលការណ៍ប្រតិបត្តិនៃការវាយតម្លៃលិខិតបទដ្ឋានគតិយុត្ត(RIA)ទាំង៧ (ត)

៥/ ការពិគ្រោះយោបល់៖ ធ្វើការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធក្នុងអំឡុងពេលធ្វើ PA ឬ RIS ។

# គោលការណ៍ប្រតិបត្តិនៃការវាយតម្លៃលិខិតបទដ្ឋានគតិយុត្ត(RIA)ទាំង៧ (ត)

៦/ សេចក្តីសន្និដ្ឋានៈ ជាការកំណត់ជម្រើសណាមួយដែលល្អ និងមានប្រសិទ្ធភាពខ្ពស់ ដើម្បីសម្រេចគោលដៅ នៃការអន្តរាគមន៍ និងផ្តល់នូវផលចំណេញខ្ពស់ ក្នុងនោះត្រូវពិនិត្យលើ៖

# ៦/ សេចក្តីសន្និដ្ឋានៈ (ត)

1. សង្ខេបការចំណាយបន្ថែម និងផលចំណេញ
2. តើត្រូវចាំបាច់ធ្វើ RIS ឬទេ ?
3. អត្ថាធិប្បាយអំពីជម្រើស

# គោលការណ៍ប្រតិបត្តិនៃការវាយតម្លៃលិខិតបទដ្ឋានគតិយុត្ត(RIA)ទាំង៧ (ក)

៧/ ការអនុវត្តៈតើជម្រើសដែលល្អ និងមានប្រសិទ្ធភាពខ្ពស់ ដែលឃើញថាផ្តល់នូវផលចំណេញខ្ពស់នោះ នឹងត្រូវបានអនុវត្តនិងវាយតម្លៃ យ៉ាងដូចម្តេច

# ៧/ ការអនុវត្ត:(ត)

1. តើវិធានការអ្វី ដែលត្រូវបានជ្រើសរើស ដើម្បីលើកកម្ពស់តម្លាភាព និងអភិបាលកិច្ចល្អក្នុងកំឡុងពេលនៃការប្រតិបត្តិ ?
2. ការពិនិត្យបញ្ញត្តិកម្មឡើងវិញ តើបញ្ញត្តិកម្មនេះ គួរត្រូវបានពិនិត្យឡើងវិញយ៉ាងដូចម្ដេច និងនៅពេលណា ?

# ទិដ្ឋភាពរួមនៃដំណាក់កាលអនុវត្ត RIA



# ទម្រង់សម្រាប់វិភាគ RIA

## (RIA Template) ៖

1. ទម្រង់ធ្វើ PA
2. ម៉ូដែលសម្រាប់វិភាគបន្ទុកចំណាយនិងផលចំណេញ(Costs and Benefit Model )

# របាយការណ៍វាយតម្លៃបឋម
# ( PA )លើអនុក្រឹត្យស្តីពីការ
# គ្រប់គ្រងសត្តឃាតដ្ឋាន
# ការត្រួតអនាម័យសត្វ សាច់
# និងផលិតផលសត្វ

# សេចក្ដីផ្ដើម

ការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ មានគោលបំណងលើកកម្ពស់សុវត្ថិភាពផលិតផលសាច់សត្វនិងបរិស្ថានឲ្យបានជាអតិបរិមា ។ អាជីវករប្រកបរបរពិឃាតសត្វសម្រាប់ផ្គត់ផ្គង់ទីផ្សារត្រូវសុំការអនុញ្ញាត ពីអាជ្ញាធរមានសមត្ថកិច្ច ក្នុងដំណើរការរបស់ខ្លួន។នេះជាប្រធានបទមួយដែលត្រូវបានជ្រើសរើស មកធ្វើការសិក្សា និងវាយតម្លៃបឋម ដោយប្រើប្រាស់វិធីសាស្ត្រ RIA។

# សេចក្តីផ្តើម (ត)

ក្នុងដំណើរការសិក្សានិងវិភាគលើប្រធានបទនេះ ជម្រើសមាន២ ទី១-វាយតម្លៃលើអនុក្រឹត្យស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យ សត្វ សាច់ និងផលិតផលសត្វ និងទី២-ពង្រឹងការអនុវត្តអនុក្រឹត្យលេខ២៩ចាស់ត្រូវបានយកមកពិចារណា ដើម្បីដោះស្រាយបញ្ហា និងសម្រេចគោលបំណងដែលចង់បាន។ ក្នុងដំណើរការRIAការវិភាគបន្ទុកចំណាយនិងផលចំណេញ (CBA) គឺជាធាតុដ៏សំខាន់សម្រាប់វិភាគនិងថ្លឹងថ្លែងជម្រើសទាំងពីរនេះ ថាតើជម្រើសមួយណាផ្តល់ផលចំណេញ ច្រើនជាងដល់សង្គមនិយាយជារួម។ លទ្ធផលនៃការសិក្សាវាយតម្លៃបឋមមានដូចខាងក្រោម៖

## ១. ការកំណត់បញ្ហា

បញ្ហាសុខភាពសាធារណៈ ការបរិភោគសាច់សត្វផ្ទុកដោយមេរោគដែលគ្មានការត្រួតពិនិត្យបានប៉ះពាល់ដល់ សុខភាព។ កន្លងមក តាមរបាយការណ៍បង្ហាញឱ្យឃើញថាប្រភេទជំងឺផ្តាសាយបក្សីដែលជាជំងឺកាចសាហាវឆ្លងពីសត្វទៅមនុស្ស តាមរយៈការប៉ះពាល់បក្សីដោយផ្ទាល់ និងការបរិភោគសាច់បក្សីផ្ទុកជំងឺផ្តាសាយបក្សី កំពុងរីករាលនៅលើពិភពលោក បណ្តាលមនុស្សបាត់បង់ជីវិតអស់ចំនួន ៣៧៥នាក់ ក្នុងនោះប្រទេស កម្ពុជាមានប្រជាពលរដ្ឋបានស្លាប់ដោយជំងឺកាចសាហាវនេះ ចំនួន២៩នាក់។ គេពិនិត្យឃើញថា ក្រៅពីជំងឺផ្តាសាយបក្សី ក៏មានសាច់សត្វគោ ក្របីមានជំងឺ បានធ្វើឱ្យអ្នកបរិភោគមានជំងឺ ក្នុងនោះ មាន ជំងឺ

# ការកំណត់បញ្ហា (ត)

ប៉េះគោ ក្របី ជំងឺរលាកស្រោមសួតគោ ក្របី ជំងឺប៉េះជ្រូក ជំងឺឈាមខ្មៅ ជំងឺផ្តួត ជំងឺបូសខ្យល់ ជំងឺសាទឹក ជំងឺចុងអង្គរ ជាដើម។ ជំងឺទាំងនេះ មានលក្ខណៈកាចសាហាវ និងឆ្លងរាតត្បាតឆាប់រហ័សបំផុតគ្មានព្រំដែនកំណត់ជាក់លាក់ និងធ្វើឲ្យមានផលវិបាកខ្លាំងដល់សេដ្ឋកិច្ចសង្គមនិងសុខភាពសាធារណៈ ពិសេសលើការធ្វើពាណិជ្ជកម្មអន្តរជាតិសត្វ និងផលិតផលមានដើមកំណើតពីសត្វ ។ (របាយការណ៍បូកសរុបការងារកសិកម្មឆ្នាំ ២០០៨ និងរបាយការណ៍របស់អង្គការសុខភាពពិភពលោក)។

# ការកំណត់បញ្ហា (ត)

បញ្ហាបរិស្ថានៈ ការសម្លាប់សត្វគ្មានការអនុញ្ញាត គ្មានបទដ្ឋានបច្ចេកទេស គ្មានការត្រួតពិនិត្យពីសមត្ថកិច្ចផលិតកម្ម និងបសុព្យាបាលធ្វើឱ្យកាកសំណល់ នៃការសម្លាប់មាន់ ទា គោក្របី ត្រូវបានអ្នកពិឃាតទុកចោលរាយប៉ាយ បានបង្កផលប៉ះពាល់ដល់បរិស្ថានសង្គម និងការរស់នៅរបស់ប្រជាពលរដ្ឋ។ កត្តាប៉ះពាល់ដល់បរិស្ថានរស់នៅមានដូចជា ក្លិនស្អុយ ការបង្ហូរទឹកក្រខ្វក់ សម្លេងសត្វស្រែក ការចម្លងមេរោគតាមខ្យល់ជាដើម ។

# ការកំណត់បញ្ហា (គ)

**ការប្រកួតប្រជែង:** ការធ្វើអាជីវកម្មសាច់សត្វបានប្រឈមនឹងរបាំងពាណិជ្ជកម្ម នៃការចូលក្នុងទីផ្សារ ព្រោះតាមការអង្កេតឃើញថា ក្នុងមួយស្រុកក្រុង អនុញ្ញាតឱ្យមានកន្លែងពិឃាតសត្វ ឬសត្តឃាតដ្ឋានតែមួយកន្លែង ធ្វើឱ្យអ្នកទទួលបានសិទ្ធិធ្វើអាជីវកម្ម ប្រើប្រាស់អំណាចទីផ្សារ។ ករណីនេះ បានប៉ះពាល់ដល់ដំណើរការប្រកួតប្រជែងក្នុងរបបទីផ្សារសេរី ។

# ការកំណត់បញ្ហា (គ)

**កង្វះព័ត៌មានៈ** ក្រសួងជួបការលំបាកក្នុងការទទួលបាន ព័ត៌មានពាក់ព័ន្ធនឹងស្ថិតិសត្តឃាតដ្ឋាន និងស្ថិតិសត្វបានសម្លាប់ប្រចាំថ្ងៃ ខែ ត្រីមាស ឆមាសនិងប្រចាំឆ្នាំ ។

# លិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ ដែលពាក់ព័ន្ធ

១.អនុក្រឹត្យលេខ២៩អនក្រ ចុះថ្ងៃទី២២ ខែវិច្ឆការ ឆ្នាំ១៩៩០ស្តីពីសត្តឃាតដ្ឋាននិងកន្លែងពិឃាតសត្វ

២.សារាចរណែនាំលេខ៤១៩ កសក.សរណន ចុះថ្ងៃទី១៤/១២/១៩៩០ ។

៣.សេចក្តីណែនាំលេខ៥១៣សនណ.កសកចុះថ្ងៃទី០៥ខែកញ្ញាឆ្នាំ២០០០ ស្តីពីបែបបទបង្កើតគ្រប់គ្រង សត្តឃាតដ្ឋាន កន្លែងពិឃាតសត្វ និងការធ្វើអាជីវកម្មពិឃាតសត្វ ។

៤.ប្រកាសលេខ០៨៦ ប្រក.កសក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីអាករអនាម័យសត្វ និងផលិតផល មានដើមកំណើតពីសត្វ ។

យោងតាមលិខិតបទដ្ឋានមានស្រាប់នេះ គេបានសង្កេតឃើញថា មានលក្ខណៈចង្អៀត ខ្វះការប្រកួតប្រជែង និងមិនទាន់សមស្របតាមរបត់សេដ្ឋកិច្ចទីផ្សារសេរី ដែលធ្វើឱ្យវិស័យសត្តឃាតដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា មានភាពមិនទាន់សម័យ ខ្វះបទដ្ឋានបច្ចេកទេសនិងស្តង់ដារ មិនឆ្លើយតបនឹងតម្រូវការទីផ្សារដែលធ្វើឲ្យវិស័យនេះ ខ្វះភាពប្រកួតប្រជែង។ ដូចនេះការធ្វើសុក្រឹត្យកម្មវិស័យនេះ ជាការចាំបាច់។

## ២. គោលបំណង

លើកកម្ពស់សុវត្ថិភាពផលិតផលសាច់សត្វ និង បរិស្ថានឲ្យបាន អតិបរិមា ។

## ៣. ជម្រើស

១.សំណើបញ្ញត្តិកម្ម ( សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផសត្វ )

២. ពង្រឹងការអនុវត្តលិខិតបទដ្ឋាន មានស្រាប់ ដោយលើកកម្ពស់ការយល់ដឹងអំពីការធ្វើអាជីវកម្មពិឃាតសត្វ ។

# ៤. ការប៉ាន់ស្មានបឋមលើចំណាយភាគពួកិច្ច និងផលចំណេញ

## ក.១.បន្ទុកចំណាយរបស់ផ្នែកធុរកិច្ច៖

ជំរើសទី១ តាមការវិភាគអំពីបន្ទុកចំណាយលើជម្រើសទី១នេះ ឃើញថា ធុរកិច្ចបានចំណាយអស់ចំនួន ៦ ៣៨២ ២៩៣ ដុល្លារ ស្មើនឹង៨៣% នៃបន្ទុកចំណាយសរុប ដែលម្ចាស់សត្តដ្ឋាន១ ត្រូវចំណាយជាមធ្យម ៥២៧៤៦ ដុល្លារ ។ ប៉ុន្តែ អាជីវករវិនិយោគក្នុងឆ្នាំដំបូងអស់ជាមធ្យម ៥០ ០០០ដុល្លារ លើការសាងសង់សត្តឃាតដ្ឋានមួយកន្លែង ហើយអាចធ្វើអាជីវកម្មជារៀងរហូត ដោយគ្រាន់តែសុំបន្តលិខិតអនុញ្ញាតក្នុងពេល៥ឆ្នាំម្តង។ ដូច្នេះសត្តឃាតដ្ឋាន១ ដើម្បីអនុវត្តតាមបញ្ញត្តកម្ម ចំណាយត្រឹមតែ ២ ៧៤៦ដុល្លារប៉ុណ្ណោះបើដកថ្លៃការសាងសង់ចេញ។ ម្យ៉ាងទៀតជាមធ្យមក្នុង១ថ្ងៃ សត្តឃាតដ្ឋាន១អាចពិឃាតគោបាន៣ក្បាល និងជ្រូក២២ក្បាល ដែលអាចរកប្រាក់ចំណេញប្រមាណ ៥៤៧០ដុល្លាក្នុង១ខែ បើតាមលទ្ធផលសម្ភាសន៍ជាមួយអាជីវករ មន្ត្រីបសុព្យាបាលមានសមត្ថកិច្ច និងសមត្ថកិច្ចពាក់ព័ន្ធ។

# បន្ទុកចំណាយរបស់ផ្ទែកធុរកិច្ចៈ

ជំរើសទី២ អាជីវករមិនបានរងនូវបន្ទុកចំណាយលើបែបបទលិខិតអនុញ្ញាតនានាទេ ដោយគ្រាន់តែមានចំណាយរដ្ឋបាលក្នុងការចូលរួម ក្នុងដំណើរការផ្សព្វផ្សាយប៉ុណ្ណោះ និងការសាងសង់សត្តឃាតដ្ឋានបន្ថែមចំនួន៤០ ដោយផ្អែកលើតម្រូវការទីផ្សារ។ យើងឃើញថា ៣០៧ ធុរកិច្ចមានបន្ទុកចំណាយ ៩៨៣ ៥៥៣ដុល្លា ក្នុងនោះធុរកិច្ច១ជាមធ្យម មានបន្ទុកចំណាយ ៣២០៤ដុល្លារ ដែលជាចំណាយបន្ថែម (incremental cost) លើបទដ្ឋានចាស់ រីឯប្រាក់ចំណេញមានកម្រិតខ្ពស់ ព្រោះធុរកិច្ចនិមួយៗ មិនបានរងបន្ទុកចំណាយកតព្វច្រើនដូចជម្រើសទី១ទេ។

# ក.២.បន្ទុកចំណាយរបស់ផ្នែករដ្ឋាភិបាល៖

ជំរើសទី១៖ រដ្ឋាភិបាល ចំណាយចំនួន ១ ២៩១ ៥១៨ ដុល្លារ ស្មើនឹង១៧% នៃចំណាយសរុប ស្មើនឹង៧% នៃថវិកាប្រចាំឆ្នាំរបស់ កសក ដែលជាតួលេខមួយខ្ពស់។

ជំរើសទី២ ៖រដ្ឋាភិបាលចំណាយ ៨៩ ៧៥៩ ដុល្លារ បើប្រៀបធៀបនឹងថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្មើនឹង ០,០០៣%ប៉ុណ្ណោះ ដែលជាទំហំនៃការចំណាយ មិនគួរឱ្យកត់សម្គាល់ឡើយ ។

## ខ.ផលចំណេញ

ជំរើសទី១ មានផលចំណេញច្រើនដូចខាងក្រោម ៖

- ការពារបរិស្ថាន និងទប់ស្កាត់បាននូវការរីករាលដាលនៃជំងឺឆ្លងពីសត្វទៅមនុស្ស

-ធ្វើឱ្យសាច់សត្វមានសុវត្ថភាព និងបង្កើនទំនុកចិត្តដល់អ្នកប្រើប្រាស់

-បង្កើនការប្រកួតប្រជែង តាមរបត់សេដ្ឋកិច្ចទីផ្សារ

-ធ្វើឱ្យមានប្រសិទ្ធភាព ដល់ការគ្រប់គ្រង ស្ថិតិសត្តឃាតដ្ឋាន ចំនួនសត្វ និងបរិមាណសាច់សត្វនៅលើទីផ្សារ

- រដ្ឋាភិបាលទទួលបានចំណូលពីសត្តឃាតដ្ឋានដូចជាតម្លៃលិខិតអនុញ្ញាត និងសោហ៊ុយសេវាកម្មត្រួតពិនិត្យ អនាម័យសត្វ និងសាច់សត្វ ។ល។ ចំនួន ៦៥៧ ៩៨៩ដុល្លារ ដែលជាចំណូលប្រចាំឆ្នាំ (យោងតាមការគណនា)។

# ខ.ផលចំណោញ (ត)

ជំរើសទី២ មានគុណវិបត្តមួយចំនួនដូចខាងក្រោម ៖

- ការប្រកួតប្រជែងមានកម្រិតទាប និងមិនទាន់សមស្របតាមរបត់សេដ្ឋកិច្ចទីផ្សារសេរី
- បរិស្ថាន និងការរីករាលដាលនៃជំងឺឆ្លងពីសត្វទៅមនុស្សរងហានិភ័យខ្ពស់
- ការគ្រប់គ្រងសត្តឃាតដ្ឋាន ផលិតកម្មសាច់ និងស្ថិតិ មិនសមស្របនឹងកម្រិតអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន
- ការបង់ចំណូលពីសត្តឃាតដ្ឋាន ទៅក្នុងថវិកាជាតិមិនច្បាស់លាស់ ។

# ៥.សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សា និងការវិភាគយ៉ាងលម្អិតមក យើងអាចសន្និដ្ឋានបានថា ទោះបីរដ្ឋាភិបាលបានចំណាយខ្ពស់ក្នុងការដាក់ចេញនូវបញ្ញត្តិកម្មថ្មីក៏ដោយ តែបញ្ញត្តិកម្មជម្រើសទី១នេះ មានសារសំខាន់ និងចាំបាច់បំផុតក្នុងបរិបទសេដ្ឋកិច្ចសម័យបច្ចុប្បន្ន ដែលកម្ពុជាត្រូវតែធ្វើទំនើបកម្ម និងបង្កើនភាពប្រកួតប្រជែងផលិតកម្មសាច់ ក្នុងលក្ខខណ្ឌសមាហរណកម្មសេដ្ឋកិច្ចជាតិក្នុងតំបន់ និងសកលលោក និងអាចជួយការពារបរិស្ថាន ធានាសុវត្ថិភាពសាច់និងសុខភាពសាធារណៈ បានកម្រិតខ្ពស់។

# សេចក្តីសន្និដ្ឋាន(ត)

ទន្ទឹមនេះ  រដ្ឋទទួលបានការប៉ះប៉ូវវិញតាមរយៈការចេញលិខិតអនុញ្ញាត និងសោហ៊ុយសេវាកម្មត្រួតពិនិត្យ អនាម័យសត្វ និងសាច់សត្វ ។ល។ ដែលមានចំនួន ៦៥៧ ៩៨៩ ដុល្លារក្នុងមួយឆ្នាំៗ រីឯធុរកិច្ច និងអ្នកប្រើប្រាស់ ក៏ទទួលបានផលចំណេញទាំងអស់គ្នា លើសពីនេះទៀត បញ្ញត្តិកម្មនេះ អាចជួយការពារ  បរិស្ថាន និងធានាសុវត្ថិភាពសាច់ បានកម្រិតខ្ពស់។

# ៥.សេចក្ដីសន្និដ្ឋាន(ត)

បើទោះបីជម្រើសទី១ មានបន្ទុកចំណាយច្រើនជាងជម្រើសទី២ក៏ដោយ ក៏ជម្រើសទី១ នេះគួរត្រូវបានជ្រើសយកមកអនុវត្ត ពីព្រោះ វាផ្ដល់ផលចំណេញច្រើនជាងជម្រើសទី២ ដោយធានាបាននូវសុវត្ថិភាពនិងសុខភាពសាធារណៈ កាត់បន្ថយការបំផ្លាញបរិស្ថាន បង្កើនចំណូលចូលថវិការដ្ឋ បង្កើតបរិយាកាសប្រកួតប្រជែងលើកកម្ពស់សមត្ថភាពប្រកួតប្រជែងជាពិសេស បង្កើនប្រសិទ្ធភាពនៃគ្រប់គ្រងលើវិស័យនេះឲ្យកាន់តែប្រសើរ។

# ៦.ការអនុវត្ត

យន្តការតាមដានមួយ គួរត្រូវបានបង្កើតឡើង ដើម្បីពិនិត្យលទ្ធផលនៃការអនុវត្តក្នុងមួយឆ្នាំម្តង កត់ត្រាទុកនូវចំណុចខ្វះខាត នឹងស្នើកែលម្អចំណុចខ្វះខាតនេះ យ៉ាងយូររយៈពេល៥ ឆ្នាំខាងមុខ ។

# សូមអរគុណ